**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

លេខ ២៤៤/២០១៩ ស.ជណ

ថ្ងៃ ទ្វាទសីរោច ខែ ភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៩

# សេចក្តីជូនដំណឹង

## ស្តីពីការជ្រើសរើសនិស្សិត សិស្សទាំងពីរភេទ ប្រឡងចូលសិក្សាវគ្គនាយទាហានសកម្មជំនាន់ទី២៤ នាយទាហានទ័ពជើងគោកជំនាន់ទី១២ នាយទាហានបន្តវេនជំនាន់ទី១៣ និងនាយទាហានជំនាញបច្ចេកទេសយោធា

**យោង** ប្រកាសលេខ ០៦៩-០៧០-០៧១ ប្រក.កពជ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ របស់ក្រសួងការពារជាតិ ស្តីពីការជ្រើសរើស និងហ្វឹកហ្វឺននាយទាហានសកម្មជំនាន់ទី២៤ នាយទាហានទ័ពជើងគោកជំនាន់ទី១២ នាយទាហានបន្តវេនជំនាន់ទី១៣

- ប្រកាសលេខ ០៤៦ ប្រក.កពជ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩ របស់ក្រសួងការពារជាតិ ស្តីពីការជ្រើសរើសនិស្សិត សិស្សមកបណ្តុះបណ្តាលជំនាញបច្ចេកទេសយោធា នៅវិទ្យាស្ថានបច្ចេកទេសយោធាតេជោ ហ៊ុន សែន ។

គណៈកម្មការជ្រើសរើស និងត្រួតពិនិត្យលក្ខណសម្បត្តិសិក្ខាកាមមកបណ្តុះបណ្តាលនៅក្នុង និងក្រៅប្រទេស សូមជូនដំណឹងដល់បេក្ខជននិស្សិត សិស្សទាំងពីរភេទ ដែលស្ម័គ្រចិត្តចូលបម្រើការងារក្នុងក្របខ័ណ្ឌ នៃកងយោធពលខេមរភូមិន្ទ ត្រូវមកទំនាក់ទំនងនិងសុំដាក់ពាក្យចុះឈ្មោះចូលប្រឡងជ្រើសរើសវគ្គនាយទាហាន តាមប្រកាសលេខ០៦៩-០៧០-០៧១ និង០៤៦ របស់ក្រសួងការពារជាតិ ដូចមានលក្ខខណ្ឌជ្រើសរើស ទីកន្លែងនិងកាលបរិច្ឆេទដូចខាងក្រោម៖

**ក.លក្ខខណ្ឌជ្រើសរើស**

១.សញ្ជាតិខ្មែរ

២.មានអាយុពី១៨ឆ្នាំ ដល់២៥ឆ្នាំ នៅលីវ គិតត្រឹមថ្ងៃដាក់ពាក្យសុំចុះឈ្មោះចូលប្រឡង

៣.មានកាយសម្បទាគ្រប់គ្រាន់តាមតម្រូវការ ដើម្បីបំពេញមុខងារ

៤.មិនធ្លាប់ត្រូវបានតុលាការផ្តន្ទាទោស

៥.មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឡើងទៅ

៦.បុរសមានកម្ពស់ ១៦០ស.ម និងនារីមានកម្ពស់ ១៥០ស.ម ឡើងទៅ

**ខ.ទីកន្លែង និងកាលបរិច្ឆេទ**

-ការចែកពាក្យនិងទទួលពាក្យសុំចុះឈ្មោះចូលប្រឡងនឹងត្រូវចាប់ផ្តើមពីថ្ងៃទី១៩ ខែកញ្ញា ដល់ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩

-ទីកន្លែងចែកពាក្យ និងទទួលពាក្យ នៅមណ្ឌលជ្រើសរើសសាកលវិទ្យាល័យការពារជាតិ និងនៅយោធភូមិភាគទី១ ទី២ ទី៣ ទី៤ និងទី៥ ។

វិថីហ្សកឌីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖ ០២៣ ៨៨៣ ២៧៤ អ៊ីមែល៖ generalsec@mod.gov.kh

អាសយដ្ឋានទំនាក់ទំនងតាមរយៈ វិបសាយ អ៊ីម៉ែល ទូរស័ព្ទលេខ៖

- វិបសាយ www : cot.mod.gov.kh (Facebook): RCAF Cambodia
- អ៊ីម៉ែល Email : cotcambodia@mod.gov.kh
- ទូរស័ព្ទលេខ ០១២ ៩៥ ៧៤ ៨៣ / ០១៦ ៨៤ ៦៤ ៥៣/ ០៩៧ ៥៦ ៥៦ ៤១៣

បេក្ខជននិស្សិត សិស្សទាំងពីរភេទត្រូវមកទំនាក់ទំនងសាកសួរព័ត៌មានលម្អិត និងបំពេញទម្រង់បែបបទផ្សេងៗ នៅទីកន្លែងទទួលពាក្យនិងដាក់ពាក្យ នៅរៀងរាល់ម៉ោងធ្វើការ ។

**រដ្ឋលេខាធិការ ក្រសួងការពារជាតិ**

**និងជាប្រធានគណៈកម្មការ** ✓

នាយឧត្តមសេនីយ៍.ភួង_ស៊ីផាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
គណៈកម្មការជ្រើសរើសនិងត្រួតពិនិត្យលក្ខណសម្បត្តិ
សិក្ខាកាមមកបណ្តុះបណ្តាលនៅក្នុងនិងក្រៅប្រទេស
លេខ......................

ថ្ងៃ ........ ខែ ........ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ........ ខែ ........ ឆ្នាំ២០១៩

# កម្មវិធីជ្រើសរើស នាយទាហានសកម្មជំនាន់ទី២៤
# នាយទាហានទ័ពជើងគោកជំនាន់ទី១២ នាយទាហានបន្តវេនជំនាន់ទី១៣
# និងនាយទាហានជំនាញបច្ចេកទេសយោធា

| ល.រ | ខ្លឹមសារ | ទីកន្លែង | កាលបរិច្ឆេទ | | ចំនួនថ្ងៃ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | ថ្ងៃ ខែ ឆ្នាំ | ដល់ ថ្ងៃ ខែ ឆ្នាំ | | |
| ១ | រៀបចំសេចក្តីជូនដំណឹងប្រកាសផ្សព្វផ្សាយតាមវិទ្យុ-ទូរទស្សន៍ | ស្ថានីយ៍វិទ្យុ - ទូរទស្សន៍ប៉ុស្តិ៍លេខ៥ ចំនួន២លើក | ទី១. ១៦/០៩/២០១៩<br>ទី២. ១២/១២/២០១៩ | - ២៥/១០/ ២០១៩<br>- ២៦/១២/២០១៩ | ៤០ថ្ងៃ<br>១៥ថ្ងៃ | - ដំណាក់ការជ្រើសរើស<br>- មុនថ្ងៃប្រឡង៩ថ្ងៃ ដល់ចប់ការប្រឡង |
| ២ | អនុគណៈកម្មការជ្រើសរើសចែកពាក្យនិងទទួលពាក្យបេក្ខជនសុំចុះឈ្មោះចូលប្រឡង | -នៅសាកលវិទ្យាល័យការពារជាតិ(ប្រស្សឹកែវ)<br>-នៅមណ្ឌលយោធភូមិភាគទី ១,២,៣,៤,៥ | - ១៩/០៩/២០១៩ | - ១៥/១១/២០១៩ | ៥៨ថ្ងៃ | - ថ្ងៃជ្រើសរើស = ៣៥ថ្ងៃ<br>- ថ្ងៃបុណ្យ+ថ្ងៃសម្រាក = ២៣ថ្ងៃ |
| ៣ | បេក្ខជនដាក់ពាក្យចូលទៅពិនិត្យកាយសម្បទា ( បឋម ) | + នៅមណ្ឌលជ្រើសរើស ៖<br>- សាកលវិទ្យាល័យការពារជាតិ<br>- យោធភូមិភាគទី ១,២,៣,៤,៥ | - ១៩/០៩/២០១៩ | - ១៥/១១/២០១៩ | ៥៨ថ្ងៃ | - ព្រឹក៖០៧:០០ - ១១:០០នាទី<br>- ថ្ងៃពិនិត្យ = ៣៥ថ្ងៃ<br>- ថ្ងៃបុណ្យ+ថ្ងៃសម្រាក = ២៣ថ្ងៃ |
| ៤ | ប្រឡងវិញ្ញាសាចំណេះដឹងទូទៅ<br>- នាយទាហានសកម្មជំនាន់ទី២៤<br>- នាយទាហានទ័ពជើងគោកជំនាន់ទី១២<br>- នាយទាហានបន្តវេនជំនាន់ទី១៣<br>- នាយទាហានជំនាញបច្ចេកទេសយោធា | មណ្ឌលប្រឡង<br>-នៅមណ្ឌលភ្នំពេញកំណត់ពេលក្រោយ<br>-នៅមណ្ឌលយោធភូមិភាគទី ១,២,៣,៤,៥ | ពិនិត្យឈ្មោះ<br>អគារបន្ទប់<br>-២១/១២/២០១៩<br>( ថ្ងៃសៅរ៍ ) | ថ្ងៃប្រឡង<br>- ២២/១២/២០១៩<br>( ថ្ងៃអាទិត្យ ) | ០២ថ្ងៃ | ព្រឹក៖០៧:០០-១១:៣០នាទី<br>ល្ងាច៖០១:០០-០៥:៣០នាទី |

| ល.រ | ខ្លឹមសារ | ទីកន្លែង | កាលបរិច្ឆេទ | | ចំនួនថ្ងៃ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | ថ្ងៃ ខែ ឆ្នាំ ដល់ ថ្ងៃ ខែ ឆ្នាំ | | | |
| ៥ | ប្រឡងវិញ្ញាសាកីឡា<br>- នាយទាហានសកម្មជំនាន់ទី២៤<br>- នាយទាហានទ័ពជើងគោកជំនាន់ទី១២<br>- នាយទាហានបន្តវេនជំនាន់ទី១៣<br>- នាយទាហានជំនាញបច្ចេកទេសយោធា | មណ្ឌលប្រឡង<br>- នៅមជ្ឈមណ្ឌលកីឡា ខ.ភ.ម(ស្ពាតចាស់)<br>-នៅតាមមណ្ឌលប្រឡង យោធភូមិភាគទី ១,២,៣,៤,៥ | - ២៣/១២/២០១៩<br>- ២៤/១២/២០១៩<br>- ២៥/១២/២០១៩<br>- ២៦/១២/២០១៩ | | ០៤ថ្ងៃ | ព្រឹក៖០៧:០០-១១:៣០នាទី<br>ល្ងាច៖០១:០០-០៥:៣០នាទី |
| ៦ | ប្រកាសលទ្ធផលបឋម<br>- នាយទាហានសកម្មជំនាន់ទី២៤<br>- នាយទាហានទ័ពជើងគោកជំនាន់ទី១២<br>- នាយទាហានបន្តវេនជំនាន់ទី១៣<br>- នាយទាហានជំនាញបច្ចេកទេសយោធា | -នៅសាកលវិទ្យាល័យការពារជាតិ(ឫស្សីកែវ )<br>- នៅ មណ្ឌលប្រឡង យោធភូមិភាគទី ១,២,៣,៤,៥ | - ២៩/០១/២០២០ | | ០១ថ្ងៃ | |
| ៧ | បេក្ខជនប្រឡងជាប់ ពិនិត្យ ឈាម ធ្វើលិខិតថ្កោលទោសពីក្រសួងយុត្តិធម៌<br>- នាយទាហានសកម្មជំនាន់ទី២៤<br>- នាយទាហានទ័ពជើងគោកជំនាន់ទី១២<br>- នាយទាហានបន្តវេនជំនាន់ទី១៣<br>- នាយទាហានជំនាញបច្ចេកទេសយោធា | - បេក្ខជន ទៅពិនិត្យឈាមនៅមន្ទីរពេទ្យព្រះកេតុមាលា<br>- ធ្វើលិខិតថ្កោលទោសនៅសាកលវិទ្យាល័យការពារជាតិ ( ឫស្សីកែវ) | - ៣០/០១/២០២០ | -១០/០២/២០២០ | ១២ថ្ងៃ | - រៀងរាល់ថ្ងៃ<br>( ថ្ងៃសម្រាក០៤ថ្ងៃ ) |
| ៨ | ប្រកាសលទ្ធផលស្ថាពរ<br>- នាយទាហានសកម្មជំនាន់ទី២៤<br>- នាយទាហានទ័ពជើងគោកជំនាន់ទី១២<br>- នាយទាហានបន្តវេនជំនាន់ទី១៣<br>- នាយទាហានជំនាញបច្ចេកទេសយោធា | -នៅសាកលវិទ្យាល័យការពារជាតិ(ឫស្សីកែវ )<br>- នៅ មណ្ឌលប្រឡង យោធភូមិភាគទី ១,២,៣,៤,៥ | - ២១/០២/២០២០ | | ០១ថ្ងៃ | |
| ៩ | ពេលវេលា បេក្ខជនប្រឡងជាប់ជាស្ថាពរ ធ្វើដំណើរពីបណ្ដាខេត្ត មករាជធានីភ្នំពេញ ត្រៀមខ្លួនចូលសាលា | | - ២២ - ២៣ /០២/២០២០ | | | ( សៅរ៍+អាទិត្យ ) |

| ល.រ | ខ្លឹមសារ | ទីកន្លែង | កាលបរិច្ឆេទ<br>ថ្ងៃ ខែ ឆ្នាំ ដល់ ថ្ងៃ ខែ ឆ្នាំ | | ចំនួនថ្ងៃ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១០ | ប្រមូលផ្តុំបេក្ខជនស្តាប់ការណែនាំ៖<br>- នាយទាហានសកម្មជំនាន់ទី២៤<br>- នាយទាហានទ័ពជើងគោកជំនាន់ទី១២<br>- នាយទាហានបន្តវេនជំនាន់ទី១៣<br>- នាយទាហានជំនាញបច្ចេកទេសយោធា | - នៅសាកលវិទ្យាល័យការពារជាតិ | - ២៤/០២/២០២០ | | ០១ថ្ងៃ | វេលាម៉ោង០៧:០០នាទីព្រឹក |
| ១១ | បេក្ខជនចេញដំណើរទៅកាន់សាលា<br>- នាយទាហានសកម្មជំនាន់ទី២៤<br>- នាយទាហានទ័ពជើងគោកជំនាន់ទី១២<br>- នាយទាហានបន្តវេនជំនាន់ទី១៣<br>- នាយទាហានជំនាញបច្ចេកទេសយោធា | ជួបជុំនៅសាកលវិទ្យាល័យការពារជាតិ<br>-ចេញទៅ**សាលានាយទាហានសកម្ម**<br>-ចេញទៅ**វិទ្យាស្ថានទ័ពជើងគោក**<br>-ចេញទៅ**វិទ្យាស្ថានបច្ចេកទេសយោធា តេជោ ហ៊ុន សែន** | - ២៥/០២/២០២០<br>- ២៦/០២/២០២០<br>- ២៧/០២/២០២០ | | -០១ថ្ងៃ<br>-០១ថ្ងៃ<br>-០១ថ្ងៃ | វេលាម៉ោង ០៦:០០នាទីព្រឹក |

❖រាល់ព័ត៌មានពេលវេលានិងទីកន្លែងគណៈកម្មការមានសិទ្ធិកែប្រែ ក្នុងករណីចាំបាច់
និងជូនដំណឹងតាមប្រព័ន្ធផ្សព្វផ្សាយជាសាធារណៈ។

**រដ្ឋលេខាធិការ ក្រសួងការពារជាតិ**
**និងជាប្រធានគណៈកម្មការ**

**នាយឧត្តមសេនីយ៍.ភួង_ស៊ីផាន**